ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ចាម
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៖ ៣២៩
ចុះថ្ងៃទី ១២.៦.២០១២
សាលក្រមព្រហ្មទណ្ឌ
លេខ ៖ ៧២"ខ"
ចុះថ្ងៃទី ២៤.៨.២០១៧

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពង់ចាម

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅសាលជំនុំជំរះសាលាដំបូងខេត្តកំពង់ចាម នាថ្ងៃទី ២៦.៧.២០១៧ ដែលមានសមាសភាពជំនុំជំរះដូចតទៅ ៖

**ក្រុមប្រឹក្សាជំនុំជំរះ**

លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកំពង់ចាម

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ចាម 098523545

**ដើម្បីជំនុំជំរះ ៖**

សំណុំរឿងព្រហ្មទណ្ឌលេខ ៣២៩ ចុះថ្ងៃទី ១២.៦.២០១២ ដែលមានជនជាប់ចោទឈ្មោះ ៖

១-[redacted] មាស ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ កើត និងរស់នៅភូមិពងទឹក ឃុំកណ្តោលជ្រុំ [redacted] ម្តាយឈ្មោះ [redacted] ទោសពីមុន គ្មាន ។

ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ៖ ២៣២ ដ.ច ចុះថ្ងៃទី ១៣.៦.២០១២

មានមេធាវីការពារសិទ្ធិ លោក [redacted] បូរាណ និងលោក [redacted] ប៊ុណ្ណារិទ្ធ

២[redacted] ក្តាម ភេទប្រុស អាយុ ១៨ឆ្នាំ ជាតិខ្មែរ កើត និងរស់នៅភូមិពងទឹក ឃុំកណ្តោលជ្រុំ [redacted] ម្តាយឈ្មោះ [redacted] ទោសពីមុន គ្មាន ។

ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ៖ .២៣២ ដ.ច ចុះថ្ងៃទី ១៣.៦.២០១២

មានមេធាវីការពារសិទ្ធិ លោក [redacted] បូរាណ

៣-[redacted] ចុនា ភេទប្រុស អាយុ ១៦ឆ្នាំ ជាតិខ្មែរ កើត និងរស់[redacted] ស្រុកពញាក្រែក ខេត្តកំពង់ចាម មុខរបរ កសិករ នៅលីវ ឪពុកឈ្មោះ [redacted]ស៊ា"រ" ម្តាយ ឈ្មោះ [redacted] ទោសពីមុន គ្មាន ។

ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ៖ .២៣២ ដ.ច ចុះថ្ងៃទី ១៣.៦.២០១២

មានមេធាវីការពារសិទ្ធិ លោក [redacted] គុជ

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃ... ខែ... ឆ្នាំ២០២..
ក្រឡាបញ្ជី

៤[redacted] ចិន ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ កើត [redacted] ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នៅលីវ ឪពុកឈ្មោះ [redacted] ជឹង "រ" ម្តាយឈ្មោះ [redacted] ទោសពីមុនគ្មាន។

ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ៖ ២៥២ ដ.ច ចុះថ្ងៃទី ១១.៧.២០១២

មានមេធាវីការពារសិទ្ធិ លោក [redacted] គុជ

៥[redacted] ប៊ី ហៅ ភ្នែក ភេទប្រុស អាយុ ២១ឆ្នាំ ជាតិខ្មែរ កើត និងរស់នៅភូមិពងទឹក ឃុំ [redacted] ម្តាយឈ្មោះ [redacted] "រ" ទោសពីមុនគ្មាន ។

ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ៖ ២៥២ ដ.ច ចុះថ្ងៃទី ១១.៧.២០១២

មានមេធាវីការពារសិទ្ធិ លោក [redacted] គុជ

៦-[redacted] សាឯម ភេទប្រុស អាយុ ២០ឆ្នាំ ជាតិខ្មែរ កើត និងរស់នៅភូមិអំពុក ឃុំកណ្តាលជ្រុំ [redacted] ម្តាយឈ្មោះ [redacted] ទោសពីមុនគ្មាន ។

ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ៖ ២៥២ ដ.ច ចុះថ្ងៃទី ១១.៧.២០១២

មានមេធាវីការពារសិទ្ធិ លោក[redacted] គុជ

ត្រូវជាប់ចោទពីបទឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិប្រធាតុ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម កាលពីថ្ងៃទី ០២.៦.២០១២ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ២០០ នៃ ក្រមព្រហ្មទណ្ឌ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ុន ភេទប្រុស អាយុ ៥៧ឆ្នាំ ជាតិខ្មែរ កើត និងរស់ នៅភូមិត្រពាំងគួ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ឪពុកឈ្មោះ [redacted] "រ" ម្តាយ ឈ្មោះ សាន់ គី "រ" ប្រពន្ធឈ្មោះ[redacted]មានកូនចំនួន ០៤នាក់ ។

ជនរងគ្រោះឈ្មោះ [redacted] ឌីព៉ក់ ភេទប្រុស កើតនៅថ្ងៃទី ០៣.៧.១៩៨៩ កើត និងរស់នៅភូមិ ត្រពាំងគួ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ឪ[redacted]នៅលីវ (ស្លាប់ក្នុងពេលកើតហេតុ) ។

ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះឈ្មោះ[redacted]លីហ៊ាង ភេទប្រុស អាយុ ២៤ឆ្នាំ ជាតិខ្មែរ កើត និងរស់នៅភូមិខ្នារ ឃុំ[redacted] ឈ្មោះ[redacted] "រ" នៅលីវ ។

ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះឈ្មោះ [redacted]ហុន ហៅ ពិត ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ កើត និងរស់[redacted] ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] " ។

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៣០៨ អយ ចុះថ្ងៃទី ១០.៤.២០១៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ចាម ។

បានឃើញដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ១២០ ពស ចុះថ្ងៃទី ២២ ខែមេសា ឆ្នាំ ២០១៣ និង លេខ ៨៥ ព.ស ចុះថ្ងៃទី ០៧.៣.២០១៤ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ចាម ។



Scanned with CamScanner

បានឃើញដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ៨០៦ ចត ចុះថ្ងៃទី ០៥.៧.២០១៣ របស់ប្រធានសាលាដំបូងខេត្តកំពង់ចាម ។

## អង្គហេតុដាក់ឲ្យស្ថិតក្រោមការពិនិត្យ

កាលពីថ្ងៃទី ០២.៦.២០១២ នៅចំនុចបរិវេណផ្ទះលក់ស៊ុប និងគ្រឿងក្លែម យីហោ ៨៨ ខាងកើតផ្លូវបំបែក ក្នុងភូមិប្រធាតុ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម មានក្រុមក្មេង ០២ក្រុមផ្សេងគ្នា បានអង្គុយស៊ីផឹកតែក្បែរគ្នា ។ ក្នុងពេលស៊ីផឹកនោះ ក្រុមទាំង ០២ក្រុមបាន ឌឺដងដាក់គ្នាទៅវិញទៅមករឿងស្រីបំរើដោយលំអៀង ជាហេតុធ្វើអោយភាគីម្ខាងមានការខឹងសម្បាមានគំនុំក្នុងចិត្ត ។ ក្រោយពេលស៊ីផឹកចប់ ភាគីក្មេង ០១ក្រុម មានគ្នា ០៦នាក់ ដែលមាន ឈ្មោះ [redacted]នា ឈ្មោះ [redacted] មាស ឈ្មោះ [redacted]ក្លាម និងបីនាក់ទៀតមិនស្គាល់ឈ្មោះ បានជិះម៉ូតូ ០២គ្រឿងម៉ាកហុងដាសេ ១២៥ និងម៉ាកអេរ៉ប្លែងចេញទៅមុន ។ លុះវេលាម៉ោង ២១ និង ០០នាទី ថ្ងៃដដែលក្រុមក្មេងដែលជាគូរបដិបក្ខ ០៣នាក់ មានឈ្មោះ[redacted]ឌីរ៉ាក់ ភេទប្រុស អាយុ ២៣ឆ្នាំ ឈ្មោះ [redacted]លឹមហួន ភេទប្រុស អាយុ ២៦ឆ្នាំ និងឈ្មោះ [redacted] លីហ៊ាង ភេទប្រុស អាយុ ២៨ឆ្នាំ បានចេញពីកន្លែងផឹកស៊ីនោះ ត្រឡប់មកផ្ទះវិញ ដោយជិះម៉ូតូ ០២គ្រឿង តាមបណ្ដោយផ្លូវជាតិលេខ ៧ ។ លុះពេលជិះមកដល់ចំនុចបង្គោលភ្លើងលេខ ៣៩១ ភូមិប្រធាតុ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ស្រាប់តែក្រុមរបស់ឈ្មោះ ស៊ីង ផុនា ឈ្មោះ [redacted] ក្លាម ឈ្មោះ[redacted]មាស និងបក្សពួកបីនាក់ទៀត បានស្ទាក់វាយតាមផ្លូវ បណ្ដាលឲ្យឈ្មោះ [redacted]ឌីរ៉ាក់ ស្លាប់ភ្លាមៗ នៅកន្លែង ឯឈ្មោះ[redacted]លឹមហួន និងឈ្មោ[redacted]លីហ៊ាង រងរបួស។ ក្រោយពេលវាយទៅលើជនរងគ្រោះបណ្ដាលឲ្យស្លាប់និងរបួសរួចហើយក្រុមជនល្មើសឈ្មោះ [redacted] ផុនា ឈ្មោះ[redacted]មាស និងឈ្មោះ [redacted]ក្លាម ព្រមទាំងបក្សពួក បាននាំគ្នារត់គេចខ្លួនអស់។ សមត្ថកិច្ចបានធ្វើការចុះពិនិត្យដល់កន្លែងកើតហេតុ និងបានកសាងសំណុំរឿងបញ្ជូនមកកាន់សាលាដំបូងខេត្តកំពង់ចាមតាមច្បាប់។

## អង្គច្បាប់ដែលដាក់ឲ្យស្ថិតក្រោមការពិនិត្យ

មាត្រា ២០០ នៃក្រមព្រហ្មទណ្ឌចែងថា ៖

ឃាតកម្មគិតទុកជាមុន គឺអំពើសម្លាប់មនុស្សដោយគិតទុកជាមុន ឬដោយការពួនស្ទាក់។

ការគិតទុកជាមុន គឺជាគម្រោងដែលបង្កើតឡើងមុន អំពើបៀតបៀននៅលើរូបបុគ្គលនៃជនរងគ្រោះ។

ការពួនស្ទាក់ គឺជាអំពើឃ្លាំចាំបុគ្គលណាម្នាក់ ក្នុងរយៈពេលមួយរយៈ ដើម្បីប្រព្រឹត្តអំពើបៀតបៀនទៅលើរូបបុគ្គលនៃជនរងគ្រោះ។

ឃាតកម្មគិតទុកជាមុន ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។

## អង្គហេតុដែលបានលើកឡើងនាពេលសវនាការ

-ដើមបណ្ដឹងរដ្ឋប្បវេណី និងជាជនរងគ្រោះឈ្មោះ[redacted]លីហ៊ាង បំភ្លឺថា ៖ នៅថ្ងៃកើតហេតុ ខ្លួននិងមិត្តភ័ក្រនាំគ្នាទៅហូបស៊ុបនៅ ៨៨ មានឈ្មោះ[redacted] ឌីរ៉ាក់(អ្នកស្លាប់) ឈ្មោះ[redacted] ឈ្មោះ ហុច ឈ្មោះ រុន ឈ្មោះ ហួន([redacted] លឹមហួន) និងរូបខ្លួនផ្ទាល់ ។ ពួកខ្លួនបានហៅស្រាមកផឹក និងមានស្រីមកបំរើស្រា ពេលនោះអ្នកផឹកជិតនឹងចេះតែមើលមុខ និងនិយាយឌឺដងដាក់ពួកខ្លួនទាក់ទងនឹងរឿងស្រី ១ ដែលគេមកបំរើស្រានោះ តែមិនមានរឿងអ្វីកើតឡើងទេ ។ បន្ទាប់មកពួកខ្លួនក៏នាំគ្នាគិតលុយត្រឡប់មកផ្ទះ។ ខ្លួន និងឈ្មោ[redacted] លឹមហួន ជិះម៉ូតូ ០១នាក់(នៅភូមិជាមួយគ្នា) ឯឈ្មោះ [redacted]រ:



Scanned with CamScanner

[redacted]

ជិះម៉ូតូ ០១ម្នាក់ឯង ចំណែក ០៣នាក់ ទៀត ជិះម៉ូតូ ០១ គ្នាបីនាក់ ជិះបត់ទៅខាងកណ្ដាលជ្រុំ។ ពេលខ្លួនជិះម៉ូតូមកដល់ចំណុចកាហ្វេសសាំងហេង ហេង ត្រង់ផ្លូវកែងប្រធាតុបត់ចូលទៅស្រុកតំបែរ មានម៉ូតូ ០១គ្រឿង ជិះគ្នា ០៣នាក់ ហើយអ្នកដែលជិះក្រោយគេបានយកដំបងវាយខ្លួន និងឈ្មោះ [redacted] លឹមហួន មួយដំបង ។ ក្នុងចំណោម ០៣នាក់ ដែលជិះម៉ូតូនេះ ខ្លួនស្គាល់តែម្នាក់ទេ គឺឈ្មោះ [redacted]ថុនា ជិះក្រោយគេ និងបានយកដំបងវាយខ្លួន ។ ពេលនោះខ្លួនក៏ឈប់ម៉ូតូតតាំងជាមួយពួកវាវិញ ខ្លួនបានដកខ្សែ ក្រវ៉ាត់វាយឈ្មោះ [redacted] ថុនា វិញ ធ្វើឲ្យរបូតក្បាលខ្សែក្រវ៉ាត ចំណែក ០២នាក់ទៀត ខ្លួនមិនស្គាល់ទេ ហើយអ្នកទាំង ០២នាក់នោះ អត់មានដំបង ឬអាវុធអ្វីទេ ពេលនោះ ខ្លួនឃើញម៉ូតូរបស់ឈ្មោះ [redacted] ឌីរ៉ាក់ បកត្រឡប់ក្រោយមកជួយខ្លួន ហើយពេលឈ្មោះ [redacted] ឌីរ៉ាក់ មកដល់ ម៉ូតូទី ២ គ្នារបស់វាក៏មកដល់ដែរ ខ្លួនក៏បានប្រតាយប្រតប់ជាមួយម៉ូតូទី ២ នេះ គឺជាមួយឈ្មោះ [redacted] ក្ដាម ដោយឈ្មោះ [redacted] ក្ដាម ប្រតាយប្រតបជាមួយគ្នាខ្លួនហើយ ទើបរត់មករកខ្លួន ។ ម៉ូតូដែលមកក្រោយនេះ ខ្លួនស្គាល់តែឈ្មោះ [redacted] ក្ដាម ម្នាក់ប៉ុណ្ណោះ អ្នកផ្សេងទៀត ខ្លួនមិនស្គាល់ទេ ។ ពេលនោះ ខ្លួនក៏ចេញពីឈ្មោះ [redacted] ថុនា មកប្រតាយប្រតប់ជាមួយឈ្មោះ [redacted] ក្ដាម ហើយត្រូវឈ្មោះ [redacted] ក្ដាមចាក់ខ្លួន ចំនួន ០៦ពន្លាក ។

[redacted]

ពេលដែលខ្លួនប្រតាយប្រតប់ជាមួយឈ្មោះ [redacted] ក្ដាម នេះវាយនឹងដៃ ព្រោះពេលវាយឈ្មោះ ស៊ឹង ថុនា នោះបានរបូតក្បាលខ្សែក្រវ៉ាតបាត់ហើយ ។

ឈ្មោះ [redacted] ឌីរ៉ាក់ ប្រតាយប្រតប់គ្នាជាមួយគេ នៅឆ្ងាយពីខ្លួន មានចំងាយពីខ្លួនប្រហែល ០៧ម៉ែត្រ តែមិនបានមើលថា អ្នកវាយជាមួយឈ្មោះ [redacted] ឌីរ៉ាក់ មានអាវុធ ឬអត់ទេ ព្រោះរវល់តែជាប់ដៃវាយជាមួយឈ្មោះ [redacted] ក្ដាម ។

ឈ្មោះ [redacted] ក្ដាម ជិះម៉ូតូទី ២ វាបានទៅប្រតាយប្រតប់ជាមួយគ្នាខ្លួនផ្សេងទៀតរួចទើបវារត់មកប្រតាយប្រតប់ជាមួយខ្លួន ។ [redacted]

ចំលើយដែលខ្លួនឆ្លើយនៅពេលនេះជាចំលើយពិត និងសូមយកតាមចំលើយនេះ អ្នកដែលវាយខ្លួនដំបូងគេគឺឈ្មោះ [redacted] ថុនា អង្គុយក្រោយគេ មិនមែនឈ្មោះ [redacted] មាស ទេ បន្ទាប់មកខ្លួនត្រូវឈ្មោះ [redacted] ក្ដាម ចាក់ចំនួន ០៦ពន្លាក ចំណែកអ្នកផ្សេងខ្លួនមិនបានប្រតាយប្រតប់ជាមួយទេ ។

ខ្លួនមិនដែលមានទំនាស់អ្វីជាមួយនឹងពួកវាទេពីមុនមក ។

ក្នុងរឿងនេះ ខ្លួនប្ដឹងទាមទារសំណងជំងឺចិត្តចំនួន ១៥.០០០(មួយម៉ឺនប្រាំពាន់)ដុល្លាអាមេរិក។ ខ្លួនប្ដឹង ទាមទារពីជនល្មើសទាំង ០៦នាក់ មិនមែនទាមទារតែពីឈ្មោះ [redacted] ថុនា និងឈ្មោះ [redacted] ក្ដាម ទេ។

**-ដើមបណ្ដឹងរដ្ឋប្បវេណី និងជាជនរងគ្រោះឈ្មោះ [redacted] លឹមហួន ហៅ ពិត បំភ្លឺថា ៖** នៅថ្ងៃកើតហេតុ ម៉ោងប្រហែល ៧យប់ឈ្មោះ [redacted]បីហ៊ាង ហៅទៅញ៉ាំស៊ុប ខ្លួនក៏ទៅ ទៅដល់ខ្លួនអត់ស្គាល់មនុស្ស ០២នាក់ ស្គាល់តែឈ្មោះ [redacted] ឌីរ៉ាក់(អ្នកស្លាប់) ឈ្មោះ រិទ្ធ និងឈ្មោះ រុន ។ ពេលពួកខ្លួនចូលទៅដល់ក្នុងហាងបានឃើញឈ្មោះ [redacted] មាស និងបក្សពួកគេសរុបទាំងអស់ ០៦នាក់ កំពុងផឹកស៊ីនៅក្នុងហាងនោះដែរ ។ ក្នុងចំណោមអ្នកទាំង ០៦នាក់នោះ ខ្លួនស្គាល់តែឈ្មោះ [redacted] មាស ម្នាក់ទេ រស់នៅភូមិពងទឹក ។ នៅពេលនាំគ្នាផឹកស៊ីនោះ គឺមិនមានរឿងវាយគ្នាទេ តែខាងគេនោះចេះតែដៀមដាមមកខាងខ្លួនពីរឿងស្រីបំរើស្រាបៀរ ។ បន្ទាប់ពីផឹកស៊ីរួចមក ពួកខ្លួនបាននាំគ្នាគិតលុយចេញមកផ្ទះ ឈ្មោះ រុន ឈ្មោះ រិទ្ធ និងម្នាក់ទៀតបានជិះបែកទៅខាងភូមិកណ្ដាលជ្រុំ



Scanned with CamScanner

ចំណែកខ្លួន និងឈ្មោះ [redacted] លីហ៊ាង ឈ្មោះ [redacted] ឌីភ៉ក់ ជិះម៉ូតូ ០២គ្រឿង មកផ្លូវជាមួយគ្នា ព្រោះនៅភូមិជាមួយគ្នា ។ ពេលជិះជិតដល់ផ្លូវកែងប្រជាតុបត់ចូលស្រុកតំបែរ ខ្លួនឃើញពួកវា ០៦នាក់ ម៉ូតូ ០២គ្រឿង ឈប់ ពួកខ្លួនក៏ជិះហួសទៅ ពេលទៅដល់កាហ្គាសសាំងហេង ហេង ស្រាប់តែមានម៉ូតូ ០១គ្រឿង ជិះគ្នា ០៣នាក់ ឈ្មោះ [redacted] មាស អង្គុយកណ្ដាល ០២នាក់ទៀត ខ្លួនមិនស្គាល់ទេ ពេលនោះម្នាក់អង្គុយក្រោយគេបានយកដំបងឬស្សីវាយខ្លួនពីក្រោយ វាយបញ្ជិត ធ្វើឲ្យត្រូវឈ្មោះ [redacted] លីហ៊ាង ដែលជាអ្នកឌុបដែរ ឯឈ្មោះ [redacted] ឌីភ៉ក់ ជិះម៉ូតូទៅមុន ។ ពួកខ្លួនបានឈប់ម៉ូតូវាយបកវិញ ដោយយកខ្សែក្រវ៉ាត់វាយ និងស្រែកឲ្យឈ្មោះ ឌីភ៉ក់ ជួយ ឈ្មោះ ឌីភ៉ក់ ក៏បកក្រោយហើយ ម៉ូតូរបស់គ្នាវាមួយទៀតក៏មកដល់ដែរ និងបានទៅប្រតាយប្រតប់ជាមួយឈ្មោះ ឌីភ៉ក់ ។ ពេលឈប់ម៉ូតូ ខ្លួនបានប្រតាយប្រតប់ជាមួយឈ្មោះ [redacted] មាស និងគ្នាវាផ្សេងទៀត ហើយបានរត់រហូតដល់ វាលស្រែ ខ្លួនក៏ឃើញគ្នាវាមកទៀត គឺម៉ូតូទី ២ ខ្លួនក៏រត់ទៅរកកាហ្គាសសាំងដើម្បីឲ្យគេជួយ ហើយ ក៏ផ្អើលដល់អ្នកកាហ្គាសសាំង ពួកវាក៏នាំគ្នារត់អស់ទៅ ។ ខ្លួនត្រូវរបួសជាំខ្នង ដោយត្រូវគេវាយនឹងដំបង និងមុខត្រូវគេវាយត្រូវនឹងដៃ ។ ខ្លួនមិនដែលមានទំនាស់អ្វីជាមួយនឹងពួកវាទេពីមុនមក ។

ក្នុងរឿងនេះ ខ្លួនសូមប្ដឹងទាមទារសំណងជំងឺចិត្ត និងថ្លៃព្យាបាលពីជនល្មើសទាំង ០៦នាក់ ចំនួន ២០.០០០.០០០(ម្ភៃលាន)រៀល ។

**-នាយប៉ុស្ដិ៍រដ្ឋបាលស្រឡប់លោក [redacted] ថន បំភ្លឺថា ៖** នៅយប់កើតហេតុនោះ គ្រាន់តែទទួលបានដំណឹងភ្លាម ខ្លួនក៏បានដឹកនាំកំលាំងចុះទៅភ្លាម ទៅដល់ឃើញជនរងគ្រោះម្នាក់ស្លាប់ ហើយក្រុមជនល្មើសបានចាកចេញទៅបាត់ប្រហែល ១០នាទីមុន ខ្លួនក៏ឲ្យកំលាំងដេញតាម និងចាត់ចែងអ្នករបួសទៅពេទ្យ ។ ពេលកំលាំងយើងដេញដល់ផ្លូវកែងប្រជាតុក៏ទទួលបានពតិមានថា ក្រុមជនល្មើសមានម៉ូតូ ០២គ្រឿង គ្នាប្រហែល ៥-៦នាក់ ម៉ូតូមួយឡើងទៅកណ្ដាលជ្រុំ ម៉ូតូមួយឡើងទៅតំបែរ ខ្លួនក៏ត្រឡប់មកកន្លែងកើតហេតុវិញ និងសាកសួរពតិមានពីជនរងគ្រោះក៏កំណត់មុខសញ្ញាបាន និងទៅស្រាវជ្រាវដល់ភូមិអណ្ដោក ភូមិពងទឹក ភូមិត្រពាំងសង្កែ ភូមិអំពុក ហើយមានសាក្សីមួយចំនួនបានជួយបំភ្លឺ យើងក៏កំណត់មុខសញ្ញារួមមានឈ្មោះ [redacted] មាស ឈ្មោះ [redacted] ថុនា ឈ្មោះ [redacted] ភ្លាម ឈ្មោះ [redacted] ចិន ឈ្មោះ [redacted] បី ហៅ ភ្នែក និងឈ្មោះ សាឯម តែជនល្មើសបានរត់គេចខ្លួនក្រោយពេលកើតហេតុមួយថ្ងៃ ។

**-សាក្សីឈ្មោះ [redacted] វ៉ុន(ឪពុករបស់ជនរងគ្រោះឈ្មោះ [redacted] លីហ៊ាង)បំភ្លឺថា ៖** នៅថ្ងៃនោះម៉ោងប្រហែលជា ៦ល្ងាច កូនរបស់ខ្លួនឈ្មោះ [redacted] លីហ៊ាង បានសុំខ្លួនទៅហូបស៊ីបជាមួយមិត្តភ័ក្រ្ត លុះដល់ម៉ោងប្រហែល ៩យប់ ខ្លួនបានទទួលដំណឹងថា កូនខ្លួនត្រូវរបួសសន្លប់នៅកន្លែងកើតហេតុ ហើយភ្លាមនោះ ខ្លួនក៏នាំកូនចៅទៅមើល ឃើញកូនឈ្មោះ [redacted] លីហ៊ាង ត្រូវរបួសមែន ។

**-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] គុន បំភ្លឺថា ៖** ពេលកើតហេតុ ខ្លួនមិននៅកន្លែងកើតហេតុទេ ដូចនេះ ខ្លួនមិនបានឃើញហេតុការណ៍ទេ ។ ក្នុងរឿងនេះ ខ្លួនប្ដឹងសុំទាមទារសំណងជំងឺចិត្តចំនួន ២០.០០០(ពីរម៉ឺន)ដុល្លាអាមេរិក ។

-តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំថា ៖ ក្រោយពីបានស្ដាប់ចំលើយជនរងគ្រោះ និងសាក្សីមក



Scanned with CamScanner

ឃើញថា ពិតជាមានសកម្មភាពប្រវ៉ាយប្រតប់គ្នារវាងជនរងគ្រោះច្រើននាក់ និងជនជាប់ចោទច្រើននាក់ ហើយក្នុងនោះឃើញថា បានធ្វើឲ្យជនរងគ្រោះម្នាក់បានស្លាប់ និងរបួស ០២នាក់ ។ ដូចនេះ ការទទួលខុសត្រូវព្រហ្មទណ្ឌក៏មានលក្ខណៈដាច់ដោយឡែក គឺទទួលខុសត្រូវទៅលើអំពើ របស់ខ្លួនដែលបានប្រព្រឹត្តរៀង ៗ ខ្លួន ។ ហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះពិចារណា និងសម្រេចតាមច្បាប់ ។

[redacted]

-លោកមេធាវី [redacted] ប៊ុណ្ណារិទ្ធ មេធាវីការពារជនជាប់ចោទឈ្មោះ [redacted] មាស ធ្វើសេចក្តីសន្និដ្ឋានការពារថា ៖ នៅក្នុងរឿងនេះ តាមចំលើយរបស់ជនរងគ្រោះដែលមានវត្តមាននៅនឹងកន្លែងកើតហេតុបាន បង្ហាញឲ្យឃើញថា កូនក្តីរបស់ខ្លួនឈ្មោះ [redacted] មាស ពុំបានសម្លាប់ជនរងគ្រោះឈ្មោះ [redacted] ឌីរ៉ាក់ ទេ គ្រាន់តែបានប្រតាយប្រតប់ជាមួយជនរងគ្រោះម្នាក់ឈ្មោះ [redacted] លឹមហួន ប៉ុណ្ណោះ ហើយតាមចំលើយជនរងគ្រោះឈ្មោះ [redacted] លីហ៊ាង បានឲ្យដឹងថា ពេលប្រតាយប្រតប់នោះកូនក្តីរបស់ខ្លួនឈ្មោះ [redacted] មាស ពុំមានអាវុធនៅនឹងដៃទេ ។ ហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះសម្រេចឲ្យកូនក្តីរបស់ខ្លួនឈ្មោះ [redacted] មាស រួចផុតពីបទចោទប្រកាន់ និងសូមបញ្ជប់ដីកាចាប់ខ្លួន ។

-លោកមេធាវី [redacted] បូរាណ មេធាវីការពារជនជាប់ចោទឈ្មោះ [redacted] មាស ឈ្មោះ [redacted] ក្តាម និងឈ្មោះ [redacted] ចុនា ធ្វើសេចក្តីសន្និដ្ឋានការពារថា ៖ ឆ្លងតាមការសួរដេញដោលនាពេលសវនាការឃើញថា តាមចំលើយរបស់ជនរងគ្រោះដែលមានវត្តមានក្នុងពេលកើតហេតុគឺឈ្មោះ [redacted] លីហ៊ាង និងឈ្មោះ [redacted] លឹមហួន ពុំបានបញ្ជាក់ ឬកំណត់ឲ្យបានច្បាស់ជនណាបានប្រព្រឹត្តទៅលើជនរងគ្រោះដែលបានស្លាប់ទេ ការសួរដេញបានឃើញថា ជនរងគ្រោះឈ្មោះ [redacted] លីហ៊ាង បានប្រតាយប្រតប់ជាមួយឈ្មោះ [redacted] ចុនា និងជាមួយឈ្មោះ ខន ក្តាម ហើយពេលនោះ ឈ្មោះ [redacted] លីហ៊ាង ក៏បានវាយទៅលើឈ្មោះ [redacted] ចុនា វិញដែរ គឺវាយនឹងខ្សែក្រវ៉ាត់ រហូតដល់របួសក្បាលឯណោះ រីឯជនរងគ្រោះឈ្មោះ [redacted] លឹមហួន បានប្រតាយប្រតប់ជាមួយឈ្មោះ [redacted] មាស ហើយជនរងគ្រោះឈ្មោះ [redacted] លឹមហួន និងឈ្មោះ [redacted] លីហ៊ាង គ្រាន់តែរបួសប៉ុណ្ណោះ មិនបានស្លាប់បាត់បង់ជីវិតឡើយ តែការចោទប្រកាន់រួម និងចោទប្រកាន់តែម្ខាង ឯម្ខាងទៀតមិនបានចោទប្រកាន់ទេ ដូចជាអយុត្តិធម៌ចំពោះជនជាប់ចោទណាស់ ព្រោះត្រូវខាងជនរងគ្រោះវាយវិញនឹងខ្សែក្រវ៉ាត់ដែរ ។ ដូចនេះ សូមក្រុមប្រឹក្សាជំនុំជំរះសម្រេចឲ្យឈ្មោះ [redacted] មាស ឈ្មោះ [redacted] ក្តាម និងឈ្មោះ [redacted] ចុនា រួចផុតពីបទចោទប្រកាន់បទ ឃាតកម្មគិតទុកជាមុន ។

-លោកមេធាវី [redacted] គុជ មេធាវីការពារជនជាប់ចោទឈ្មោះ [redacted] ប៊ី ហៅ ភ្នែក ឈ្មោះ [redacted] ចិន និងឈ្មោះ [redacted] សាឯម ធ្វើសេចក្តីសន្និដ្ឋានការពារថា ៖ នៅក្នុងរឿងនេះ គ្មានសាក្សីណាម្នាក់បានឃើញជនជាប់ចោទឈ្មោះ [redacted] ប៊ី ហៅ ភ្នែក ឈ្មោះ [redacted] ចិន និងឈ្មោះ [redacted] សាឯម បានប្រព្រឹត្តទេ ដោយជនរងគ្រោះដែលមានវត្តនៅកន្លែងកើតហេតុស្គាល់តែឈ្មោះ [redacted] មាស ឈ្មោះ [redacted] ក្តាម និង ឈ្មោះ [redacted] ចុនា ប៉ុណ្ណោះ ។ ដូចនេះ សូមក្រុមប្រឹក្សាជំនុំជំរះពិចារណា និងសម្រេចតាមច្បាប់ ។

ក្រោយពីបានស្តាប់ចំលើយបំភ្លឺរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះ

ក្រោយពីបានស្តាប់ចំលើយបំភ្លឺរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់ចំលើយបំភ្លឺរបស់សាក្សី

ក្រោយពីបានស្តាប់ចំលើយបំភ្លឺរបស់មន្ត្រីនគរបាលយុត្តិធម៌

ក្រោយពីបានស្តាប់ការសួរដេញដោល



Scanned with CamScanner

ក្រោយពីបានពិនិត្យឯកសារភស្តុតាងនានាដែលមានក្នុងសំណុំរឿង

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**យល់ឃើញថា ៖**

-តាមដីកាបញ្ជូនរឿងទៅជំនុំជំរះរបស់ចៅក្រមស៊ើបសួរឃើញថា ឈ្មោះ [redacted]មាស ភេទប្រុស អាយុ ១៩ឆ្នាំ ឈ្មោះ [redacted] ក្តាម ភេទប្រុស អាយុ ១៨ឆ្នាំ ឈ្មោះ [redacted]ថុនា ភេទប្រុស អាយុ ១៦ឆ្នាំ ឈ្មោះ [redacted] ចិន ភេទប្រុស អាយុ ១៩ឆ្នាំ ឈ្មោះ [redacted]ប៊ី ហៅ ក្អែក ភេទប្រុស អាយុ ២១ឆ្នាំ និងឈ្មោះ [redacted]សាឯម ភេទប្រុស អាយុ ២០ឆ្នាំ ត្រូវបញ្ជូនមកជំនុំជំរះពីបទឃាតកម្មគិតទុកជាមុន អង្គហេតុកើតនៅភូមិប្រជាតុ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម កាលពីថ្ងៃទី ០២.៦.២០១២ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ ។

-ឆ្លងតាមការសួរដេញដោលនាពេលសវនាការ និងការពិនិត្យឯកសារដែលប្រមូលបាននៅដំណាក់កាលស៊ើបសួរឃើញថា ពិតជាមានអង្គហេតុវាយប្រតាយប្រតប់គ្នាដោយដៃ និងអាវុធកើតឡើងនៅពេល និងទីកន្លែងខាងលើប្រាកដមែន ។

-តាមចំលើយរបស់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] លីហ៊ាង និងឈ្មោះ [redacted] លឹមហួន បានឆ្លើយប្រហាក់ប្រហែលគ្នា ដែលបង្ហាញឲ្យឃើញពីអង្គហេតុ និងមូលហេតុដែលបានកើតឡើង គឺបណ្តាលមកក្រុមជនជាប់ចោទមិនសប្បាយចិត្តពីរឿងអ្នកបំរើស្រាបៀរបំរើលំអៀងដោយយកចិត្តទុកដាក់ខាងជនរងគ្រោះច្រើនជាងខាងខ្លួន មិនមែនកើតចេញពីគំនុំអ្វីទេ ។ ដូចនេះ តុលាការយល់ឃើញថា ចេតនារបស់ជនជាប់ចោទគឺគ្រាន់តែចង់ប្រើអំពើហិង្សាប៉ុណ្ណោះ ព្រោះថាពេលកើតហេតុដំបូង គឺមានមួយម៉ូតូទេ ដោយអ្នកជិះម៉ូតូទី ១ បានយកដំបងវាយជនរងគ្រោះពីក្រោយ តែការវាយនេះមិនបានបណ្តាលឲ្យដួលម៉ូតូ ហើយខាងជនរងគ្រោះបានឈប់ម៉ូតូវាយបកទៅលើខាងជនជាប់ចោទវិញដោយខ្សែក្រវ៉ាត់ វាយរហូតដល់របូតក្បាលខ្សែក្រវ៉ាត់ ។ ជាក់ស្តែងតាមចំលើយរបស់ជនរងគ្រោះឈ្មោះ [redacted] លីហ៊ាង បានបំភ្លឺថា ម៉ូតូទី ១ មានគ្នា ០៣នាក់ ខ្លួនស្គាល់តែឈ្មោះ [redacted] ថុនា ទេ អង្គុយក្រោយគេ បានយកដំបងវាយពីក្រោយ ឯពីរនាក់ផ្សេងទៀត មិនមានអ្វីក្នុងដៃទេ ហើយក៏មិនស្គាល់ឈ្មោះដែរ ពួកខ្លួនក៏បានឈប់ម៉ូតូ ហើយខ្លួនបានយកខ្សែក្រវ៉ាត់វាយទៅលើឈ្មោះ [redacted] ថុនា វិញ ហើយបានរបូតក្បាលខ្សែក្រវ៉ាត់ បន្ទាប់មកឈ្មោះ [redacted]ឌីរ៉ាក់ មកដល់ ហើយម៉ូតូទី ២ ក៏មកដល់ដែរ ម៉ូតូទី ២ នេះ ខ្លួនស្គាល់តែឈ្មោះ [redacted] ក្តាម ម្នាក់ទេ ឈ្មោះ [redacted]ក្តាម បានប្រតាយ ប្រតប់ជាមួយគ្នាខ្លួនរួចហើយ ទើបរត់មករកខ្លួន ១ ក៏ប្រតាយប្រតប់ជាមួយឈ្មោះ [redacted] ក្តាម ដោយដៃ ព្រោះខ្សែក្រវ៉ាត់បានរបូតក្បាលពេលវាយ ឈ្មោះ [redacted] ថុនា ហើយត្រូវឈ្មោះ [redacted] ក្តាម ចាក់ត្រូវចំនួន ០៦ពន្លាក ។ ចំណែកជនរងគ្រោះឈ្មោះ [redacted] លឹមហួន បានឲ្យដឹងថា ពេលត្រូវអ្នកជិះម៉ូតូទី ១ ដែលអង្គុយក្រោយគេវាយត្រូវហើយ ខ្លួនបានឈប់ម៉ូតូវាយវិញ ។ ខ្លួនបានប្រតាយប្រតប់ជាមួយ ឈ្មោះ [redacted]មាស ដែលអង្គុយកណ្តាលគេ និងគ្នាវាផ្សេងទៀត ហើយរត់រហូតដល់វាលស្រែ ខ្លួនឃើញឈ្មោះ [redacted] ឌីរ៉ាក់ មកដល់ ហើយម៉ូតូទី ២ ក៏មកដល់ដែរ ខ្លួនក៏រត់សំដៅរកកាហ្គាសសាំង ស្រែកឲ្យគេជួយ ក៏ផ្អើលដល់អ្នកកាហ្គាសសាំង ពួកវាក៏រត់អស់ទៅ ។



Scanned with CamScanner

ដូចនេះ តាមចំលើយរបស់ជនរងគ្រោះឈ្មោះ [redacted] លីហ៊ាង និងឈ្មោះ [redacted] លឹមហួន បង្ហាញឲ្យឃើញថា ឈ្មោះ [redacted] មាស ឈ្មោះ [redacted] ថុនា និងឈ្មោះ [redacted] ក្ដាម បានប្រព្រឹត្តអំពើហិង្សាដោយចេតនាទៅលើជនរងគ្រោះឈ្មោះ [redacted] លីហ៊ាង និងឈ្មោះ [redacted] លឹមហួន ប្រាកដមែន ។ ហេតុនេះ គប្បីតុលាការសម្រេចកែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] មាស និងឈ្មោះ [redacted] ថុនា ពីបទឃាតកម្មគិតទុកជាមុន មកជាបទហិង្សាដោយចេតនាវិញ ឯឈ្មោះ [redacted] ក្ដាម តាមចំលើយរបស់ឈ្មោះ [redacted] លីហ៊ាង និងឈ្មោះ [redacted] លឹមហួន បានឲ្យដឹងថា ពេលឈ្មោះ [redacted] ឌីរ៉ាក់ មកដល់ម៉ូតូទី ២ ដែលមានឈ្មោះ [redacted] ក្ដាម ក៏មកដល់ដែរ ។ ជាក់ស្ដែង តាមចំលើយរបស់ឈ្មោះ [redacted] លីហ៊ាង បានបញ្ជាក់ថា ឈ្មោះ [redacted] ក្ដាម បានប្រតាយប្រតប់ជាមួយគ្នាខ្លួនរួចទើបរត់មកខ្លួន រីឯឈ្មោះ [redacted] លឹមហួន បានបញ្ជាក់ថា ខ្លួនបានប្រតាយប្រតប់ជាមួយឈ្មោះ [redacted] មាស និងគ្នាវាផ្សេងទៀតរត់ដល់វាលស្រែ ក៏ឃើញម៉ូតូរបស់ឈ្មោះ [redacted] ឌីរ៉ាក់ មកដល់ ហើយម៉ូតូទី ២ ក៏មកដល់ដែរ ដែលនេះបង្ហាញឲ្យឃើញថា ឈ្មោះ [redacted] ក្ដាម បានទៅប្រតាយប្រតប់ជាមួយជនរងគ្រោះឈ្មោះ [redacted] ឌីរ៉ាក់ ដែលបានស្លាប់បាត់បង់ជីវិតនៅកន្លែងកើតហេតុដែរ ។ ដូច្នេះ តុលាការយល់ឃើញថា អំពើល្មើសរបស់ឈ្មោះ [redacted] ក្ដាម ជាអំពើហិង្សាដោយចេតនា(ករណីវាយទៅលើឈ្មោះ វ៉ុន លីហ៊ាង) និងហិង្សាដោយចេតនាបណ្ដាលឲ្យជនរងគ្រោះស្លាប់(ករណីវាយទៅលើឈ្មោះ [redacted] ឌីរ៉ាក់) ។

ហេតុនេះ គប្បីកែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ក្ដាម ពីបទឃាតកម្មគិតទុកជាមុន មកជាបទហិង្សាដោយចេតនា និងហិង្សាដោយចេតនាបណ្ដាលឲ្យជនរងគ្រោះស្លាប់(មាត្រា ២១៨ និងមាត្រា ២២៨ នៃក្រមព្រហ្មទណ្ឌ) ។

-តាមការពិនិត្យឯកសារដែលប្រមូលបាននៅដំណាក់កាលស៊ើបសួរឃើញថា គ្មានសាក្សីណាម្នាក់បានឃើញហេតុការណ៍នៅពេលវាយតប់ កាប់ចាក់នេះកើតឡើងទេ ហើយជនរងគ្រោះដែលមានវត្តមាននៅកន្លែងកើតហេតុក៏ស្គាល់ជនជាប់ចោទមិនអស់ដែរ ។ ប៉ុន្តែតាមចំលើយរបស់សាក្សីឈ្មោះ [redacted] ធុន ដែលមានផ្ទះនៅទល់មុខនឹងផ្ទះរបស់ឈ្មោះ [redacted] ក្ដាម បានបំភ្លឺថា ម៉ោងប្រហែល ១១យប់ ខ្លួនឮសំលេងឆ្កែព្រុះ ខ្លួនក៏ដឹងខ្លួន ហើយបានមើលទៅឃើញមានក្មេង ៗ ០៦នាក់ កំពុងឈរនិយាយគ្នា និងម៉ូតូ ០២គ្រឿង ខ្លួនក៏ចុះទៅមើល ឃើញពួកវាប្រឡាក់ឈាមចំនួន ០៣នាក់ គឺឈ្មោះ [redacted] ឈ្មោះ [redacted] និងឈ្មោះ ថុនា ។

ការប្រឡាក់ឈាមរបស់ឈ្មោះ [redacted] ថុនា ដែលសាក្សីបានឃើញ តុលាការយល់ថា គឺបណ្ដាលមកពីជនរងគ្រោះវាយត្រូវនឹងក្បាលខ្សែក្រវ៉ាត់វិញ ។

ឯឈ្មោះ ពៀច ដែលសាក្សីស្គាល់គឺឈ្មោះ [redacted] ប៊ី ហៅ ភ្នែក ព្រោះសាក្សីបានរៀបរាប់ថា អ្នកទាំង ០៦នាក់នោះ ឈ្មោះ ចិន ឈ្មោះ សាឯម និងឈ្មោះ ពៀច ។ ឈ្មោះ ចិន និងឈ្មោះ សាឯម នៅភូមិអំពុក ឯបួននាក់ទៀតនៅភូមិពងទឹកជាមួយខ្លួន ។ ដូចនេះ ឈ្មោះ ពៀច គឺឈ្មោះ [redacted] ប៊ី ហៅ ភ្នែក ហើយការប្រឡាក់ឈាមរបស់ឈ្មោះ [redacted] ប៊ី ហៅ ភ្នែក ដែលសាក្សីបានឃើញនេះ តុលាការយល់ថា គឺបណ្ដាលមកពីជនរងគ្រោះវាយត្រូវវិញនឹងក្បាលខ្សែក្រវ៉ាត់ ព្រោះនៅ ដំណាក់កាលស៊ើបសួរឈ្មោះ [redacted] លឹមហួន បានបញ្ជាក់ថា ខ្លួនបានយកខ្សែក្រវ៉ាត់វាយបកវិញ និង ជាមួយនឹងចំលើយនៅពេលសវនាការដែលបានបំភ្លឺថា ខ្លួនបានប្រតាយប្រតប់ជាមួយឈ្មោះ [redacted] មាស និងគ្នាវាផ្សេងទៀតមិនស្គាល់ និងបានរត់ទៅដល់វាលស្រែ ទើបឃើញឈ្មោះ [redacted] ឌីរ៉ាក់(ជនរងគ្រោះស្លាប់) និងម៉ូតូទី ២ មកដែរ ដែលតាមចំលើយរបស់ឈ្មោះ [redacted] លីហ៊ាង បញ្ជាក់ថា ម៉ូតូទី ២



Scanned with CamScanner

[redacted]

មានឈ្មោះ [redacted] ក្តាម ម្នាក់ដែលខ្លួនស្គាល់ ។ ដូច្នេះ បង្ហាញឲ្យឃើញថា ម៉ូតូទី ១ ដែលមានឈ្មោះ [redacted] មាស អង្គុយកណ្តាល ឈ្មោះ [redacted] ថុនា អង្គុយក្រោយមានដំបង និងម្នាក់ទៀតឈ្មោះ [redacted] ប៊ី ហៅ ភ្នែក បានប្រតាយប្រតប់ជាមួយជនរងគ្រោះឈ្មោះ [redacted] លីហ៊ាង និងឈ្មោះ [redacted] លឹមហួន ដោយជនរងគ្រោះឈ្មោះ [redacted] លីហ៊ាង បានប្រតាយប្រតប់ជាមួយឈ្មោះ [redacted] ថុនា ហើយឈ្មោះ [redacted] មាស និងឈ្មោះ [redacted] ហៅ ភ្នែក បានប្រតាយប្រតប់ជាមួយជនរងគ្រោះឈ្មោះ [redacted] លឹមហួន និងបានរត់ដល់វាលស្រែ និងត្រូវបានជនរងគ្រោះវាយត្រូវនឹងក្បាលខ្សែក្រវ៉ាត់ ព្រោះតាមកំណត់ហេតុពិនិត្យកន្លែងកើតហើយ សមត្ថកិច្ចបានរកឃើញខ្សែក្រវ៉ាត់ចំនួន ០២ គ្មានក្បាល និងបំណែកក្បាលខ្សែក្រវ៉ាត់ចំនួន ០២ ដែលនេះបញ្ជាក់ឲ្យឃើញថា ជនរងគ្រោះទាំងពីរនាក់បានវាយជនជាប់ចោទវិញនឹងខ្សែក្រវ៉ាត់ទាំងពីរនាក់ ។ ហេតុដូចនេះ គប្បីតុលាការកែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ប៊ី ហៅ ភ្នែក ពីបទឃាតកម្មគិតទុកជាមុន មកជាបទហិង្សាដោយចេតនា(មាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ) ។

រីឯការប្រឡាក់ឈាមរបស់ឈ្មោះ [redacted] ក្តាម គឺអាចជាឈាមរបស់ជនរងគ្រោះ ព្រោះតាមចំលើយរបស់ជនរងគ្រោះឈ្មោះ [redacted] លីហ៊ាង បានឲ្យដឹងថា ខ្លួនបានប្រតាយប្រតប់ជាមួយឈ្មោះ [redacted] ក្តាម ហើយត្រូវឈ្មោះ [redacted] ក្តាម ចាក់ត្រូវចំនួន ០៦កន្លែង ដែលបញ្ជាក់ថា ចាក់ត្រូវហើយនៅមានការប្រតាយប្រតប់គ្នាទៀត ដូចនេះធ្វើឲ្យឈាមជនរងគ្រោះមកប្រឡាក់នឹងឈ្មោះ [redacted] ក្តាម ។

សរុបមក តាមចំលើយរបស់ជនរងគ្រោះឈ្មោះ [redacted] លីហ៊ាង ឈ្មោះ [redacted] លឹមហួន និងសាក្សីឈ្មោះ [redacted] ធុន ព្រមទាំងវត្ថុតាងដែលសមត្ថកិច្ចរកឃើញនៅកន្លែងកើតហេតុអាចឲ្យតុលាការកំណត់មុខសញ្ញាជនជាប់ចោទដែលជិះម៉ូតូទី ២ និងវាយជនរងគ្រោះឈ្មោះ [redacted] ឌីរ៉ាក់ រហូតដល់ស្លាប់នោះគឺឈ្មោះ [redacted] ក្តាម ឈ្មោះ [redacted] ចិន និងឈ្មោះ [redacted] សាឯម ។ ដូច្នេះ គប្បីតុលាការកែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ចិន និងឈ្មោះ [redacted] សាឯម ពីបទឃាតកម្មគិតទុកជាមុន មកជាបទហិង្សាដោយចេតនាបណ្តាលឲ្យជនរងគ្រោះស្លាប់(មាត្រា ២២៤ នៃក្រមព្រហ្មទណ្ឌ)។

[redacted]

-ជនជាប់ចោទឈ្មោះ [redacted] មាស ឈ្មោះ [redacted] ក្តាម ឈ្មោះ [redacted] ថុនា ឈ្មោះ [redacted] ប៊ី ហៅ ភ្នែក ឈ្មោះ [redacted] ចិន ឈ្មោះ [redacted] សាឯម ជាបុគ្គលមានសតិស្មារតីល្អជា អាចពិចារណាពីការទទួលខុសត្រូវព្រហ្មទណ្ឌបាន ។

-អំពើល្មើសដែលជនជាប់ចោទឈ្មោះ [redacted] មាស ឈ្មោះ [redacted] ក្តាម ឈ្មោះ [redacted] ថុនា ឈ្មោះ [redacted] ប៊ី ហៅ ភ្នែក ឈ្មោះ [redacted] ចិន ឈ្មោះ [redacted] សាឯម បានប្រព្រឹត្តធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈយ៉ាងខ្លាំង ពិសេសរូបកាយ និងអាយុជីវិតរបស់បុគ្គលដែលច្បាប់ការពារ ។

-សេចក្តីសន្និដ្ឋានប្តឹងរបស់តំណាងអយ្យការ សុំឲ្យក្រុមប្រឹក្សាជំនុំជំរះពិចារណា និងសម្រេចតាមច្បាប់ មានលក្ខណៈត្រឹមត្រូវ គប្បីតុលាការលើកមកពិចារណា។

-សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារជនជាប់ចោទ សុំឲ្យក្រុមប្រឹក្សាជំនុំជំរះសម្រេចឲ្យជនជាប់ចោទរួចផុតពីបទចោទប្រកាន់ មានលក្ខណៈមិនត្រឹមត្រូវទេ ដោយមូលហេតុដូចមានក្នុងសំអាងហេតុខាងលើ ។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] មាស ភេទប្រុស អាយុ ១៩ឆ្នាំ ឈ្មោះ [redacted] ថុនា ភេទប្រុស អាយុ ១៦ឆ្នាំ ឈ្មោះ [redacted] ប៊ី ហៅ ភ្នែក ភេទប្រុស អាយុ ២១ឆ្នាំ ពីបទហិង្សាដោយចេតនា ឈ្មោះ [redacted] ក្តាម ភេទប្រុស អាយុ ១៨ឆ្នាំ ពីបទហិង្សាដោយចេតនា និងបទហិង្សា



Scanned with CamScanner

ដោយចេតនាបណ្ដាលឲ្យជនរងគ្រោះស្លាប់ ឈ្មោះ [redacted] ចិន ភេទប្រុស អាយុ ១៩ឆ្នាំ និងឈ្មោះ [redacted] សាងម ពីបទហិង្សាដោយចេតនាបណ្ដាលឲ្យជនរងគ្រោះស្លាប់ អង្គហេតុកើតនៅភូមិប្រធាតុ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម កាលពីថ្ងៃទី ០២.៦.២០១២ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា ២១៨ និងមាត្រា ២២៤ នៃក្រមព្រហ្មទណ្ឌ ។

-ជនជាប់ចោទឈ្មោះ [redacted] មាស និងឈ្មោះ [redacted]ប៊ី ហៅ ភ្នែក ពុំធ្លាប់ប្រព្រឹត្តអំពើល្មើសអ្វីពីមុនមក និងជាកំហុសលើកទី ១ ។ ដូចនេះ គប្បីតុលាការលើកយកមាត្រា ១០៦ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌមកពិចារណា ដោយសម្រេចឲ្យជនជាប់ចោទអនុវត្តទោសព្យួរ ។

[redacted]

-ជនជាប់ចោទឈ្មោះ [redacted] ថុនា ពេលប្រព្រឹត្តបទល្មើស ទើបតែមានអាយុ ១៦ឆ្នាំ នៅជាអនីតិជននៅឡើយ និងពុំធ្លាប់ប្រព្រឹត្តអំពើល្មើសអ្វីពីមុនមក ។ យោងតាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ គប្បីតុលាការសម្រេចឲ្យជនជាប់ទោសបន្ថយមកត្រឹមពាក់កណ្ដាលនៃទោសដែលត្រូវអនុវត្តចំពោះនីតិជន និងឲ្យអនុវត្តទោសព្យួរ យោងតាមមាត្រា ១០៦ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ ។

-ជនជាប់ចោទឈ្មោះ [redacted] ក្លាម ឈ្មោ[redacted]ចិន និងឈ្មោះ [redacted] សាងម ក្រោយពីប្រព្រឹត្តបទល្មើសបានរត់គេចខ្លួន ហើយនៅពេលនេះត្រូវបានតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារលើសពី ០១ឆ្នាំ ដោយគ្មានការព្យួរទោស ។ ហេតុនេះ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គប្បីតុលាការបង្គាប់ឲ្យចាប់ខ្លួនភ្លាម ។

-នៅពេលពិនិត្យកន្លែងកើតហេតុ សមត្ថកិច្ចបានចាប់យកព្រនង់ឬស្សីទំហំ ១,៥០ស.ម គុណ ១,២០ម៉ែត្រ ចំនួន ០១ ខ្សែក្រវ៉ាត់ពណ៌ក្រហមទំហំ ៣,៥០ស.ម គុណ ៩៤ស.ម (គ្មានក្បាល) ចំនួន ០១ ខ្សែក្រវ៉ាត់ពណ៌ខ្មៅទំហំ ៣,៥០ស.ម គុណ ១០៣ស.ម(គ្មានក្បាល) ចំនួន ០១ ស្បែកជើងសង្រែកទំហំ ៨,៥០ស.ម គុណ ២៧ស.ម(ពណ៌ខ្មៅ)ចំនួន ០១ ស្បែកជើងសង្រែកទំហំ ៨,៥០ស.ម គុណ ២៦ស.ម(ពណ៌ខ្មៅ) ចំនួន ០១ ស្បែកជើងសង្រែកទំហំ ៨,៥០ស.ម គុណ ២៧ស.ម(ពណ៌ត្រាវ) ចំនួន ០១ បំណែកក្បាលខ្សែក្រវ៉ាត់ទំហំមុខកាត់ ០,៥០ស.ម ប្រវែង ០៨ស.ម ចំនួន ០១ បំណែកក្បាលខ្សែក្រវ៉ាត់ទំហំមុខកាត់ ០,៥០ស.ម ប្រវែង ០៥ស.ម ចំនួន ០១ មួកប៉ារ៉េពណ៌សឆ្នូតខ្មៅ ផ្លាក Adidas ចំនួន ០១ ។ យោងតាមមាត្រា ២០៦ ចំណុច ៥ មាត្រា ២២៩ ចំណុច ៥ មាត្រា ៥៣ និងមាត្រា ៥៤ នៃក្រមព្រហ្មទណ្ឌ គប្បីតុលាការសម្រេចរឹបអូស ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ[redacted]តុន បានប្ដឹងទាមទារសំណងពីជនជាប់ចោទទាំង ០៦នាក់ ក្នុងម្នាក់ ១ ចំនួន ២០.០០០(ពីរម៉ឺន)ដុល្លាអាមេរិក ឈ្មោ[redacted]លីហ៊ាង បានប្ដឹងទាមទារចំនួន ១៥.០០០(មួយម៉ឺនប្រាំពាន់)ដុល្លាអាមេរិក និងឈ្មោះ [redacted] លឹមហួន បានប្ដឹងទាមទារចំនួន ២០.០០០.០០០(ម្ភៃលាន)រៀល ពីជនជាប់ចោទទាំង ០៦នាក់ ។ ការប្ដឹងទាមទារនេះ តុលាការយល់ឃើញថា មិនត្រឹមត្រូវទេ ព្រោះដើមបណ្ដឹងរដ្ឋប្បវេណីបានធ្វើការប្ដឹងទាមទារលើជនជាប់ចោទទាំងអស់ ដែលជនជាប់ចោទខ្លះមិនបានប្រព្រឹត្តលើជនរងគ្រោះផង ។ ដូចនេះ គប្បីតុលាការសម្រេចបង្គាប់ឲ្យសងតែចំពោះជនជាប់ចោទណាដែលតុលាការរកឃើញថា បានប្រព្រឹត្តទៅលើជនរងគ្រោះប៉ុណ្ណោះ ។

[redacted]



Scanned with CamScanner

**ហេតុដូច្នេះ តុលាការ**
**វិនិច្ឆ័យសេចក្តី**

១.ក.កែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ ៖

- [redacted]ាស ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ(សាវតាជាតិដូចខាងលើ)
- [redacted] ថុនា ភេទប្រុស អាយុ ១៦ឆ្នាំ ជាតិខ្មែរ(សាវតាជាតិដូចខាងលើ)
- [redacted]ប៊ី ហៅ ភ្នែក ភេទប្រុស អាយុ ២១ឆ្នាំ ជាតិខ្មែរ(សាវតាជាតិដូចខាងលើ)

ពីបទឃាតកម្មគិតទុកជាមុន(មាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ) មកជាបទហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស(មាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ) អង្គហេតុកើតនៅភូមិប្រជាតុ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម កាលពីថ្ងៃទី ០២.៦.២០១២ ។

១.ខ.ផ្តន្ទាទោសជនជាប់ចោទឈ្មោះ ៖

- [redacted]មាស ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ(សាវតាជាតិដូចខាងលើ)
- [redacted] ប៊ី ហៅ ភ្នែក ភេទប្រុស អាយុ ២១ឆ្នាំ ជាតិខ្មែរ(សាវតាជាតិដូចខាងលើ)

ដាក់ពន្ធនាគារក្នុងម្នាក់ៗ ចំនួន ០២ឆ្នាំ តាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ

- [redacted] ថុនា ភេទប្រុស អាយុ ១៦ឆ្នាំ ជាតិខ្មែរ(សាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារ ចំនួន ០១ឆ្នាំ តាមមាត្រា ២១៨ និងមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ ។

[redacted]

ពីបទហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស អង្គហេតុកើតនៅភូមិប្រជាតុ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម កាលពីថ្ងៃទី ០២.៦.២០១២ ។

ប៉ុន្តែទោសខាងលើទាំងអស់នេះ(ជនជាប់ចោទទាំង ០៣នាក់) ត្រូវព្យួរធម្មតា យោងតាមមាត្រា ១០៦ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ ។

២.បញ្ឈប់ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ៖ ២៣២ ដ.ច ចុះថ្ងៃទី ១៣.៦.២០១២ របស់ចៅក្រមស៊ើបសួរ ដែលបង្គាប់ឲ្យចាប់ខ្លួនឈ្មោះ [redacted] មាស និងឈ្មោះ [redacted]ថុនា និងដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ៖ ២៥២ ដ.ច ចុះថ្ងៃទី ១១.៧.២០១២ របស់ចៅក្រមស៊ើបសួរ ដែលបង្គាប់ឲ្យចាប់ខ្លួនឈ្មោះ [redacted] ប៊ី ហៅ ភ្នែក ។

៣.ក.បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted]មាស និងឈ្មោះ [redacted]ប៊ី សងថ្លៃព្យាបាល និងជំងឺចិត្តទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] លឹមហួន ចំនួន ២.០០០.០០០(ពីរលាន)រៀល ។ ការទាមទារលើសពីនេះ បដិសេធចោល ។

៣.ខ.បង្គាប់ឲ្យអ្នកទទួលខុសត្រូវរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ា និងប្រពន្ធឈ្មោះ [redacted] ខេង ដែលជាឪពុកម្តាយរបស់ជនជាប់ចោទឈ្មោះ[redacted]ថុនា សងថ្លៃព្យាបាល និងជំងឺចិត្តទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]លឹមហួន និងឈ្មោះ[redacted]លីហ៊ាង ក្នុងម្នាក់ៗ ចំនួន ៣.០០០.០០០(បីលាន) រៀល ។ ការទាមទារលើសពីនេះបដិសេធចោល ។

៤.ក.កែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted]ក្លាម ភេទប្រុស អាយុ ១៨ឆ្នាំ ពីបទឃាតកម្មគិតទុកជាមុន(មាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ) មកជាបទហិង្សាដោយចេតនាមានស្ថាន



Scanned with CamScanner

ទម្ងន់ទោស(មាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ) និងបទហិង្សាដោយចេតនា បណ្តាលឲ្យជនរងគ្រោះស្លាប់ (មាត្រា ២២៤ នៃក្រមព្រហ្មទណ្ឌ) ។

៤.ខ.ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted]ភ្លាម ភេទប្រុស អាយុ ១៨ឆ្នាំ ដាក់ពន្ធនាគារចំនួន ១៣ឆ្នាំ ពីបទហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងបទហិង្សាដោយចេតនាបណ្តាលឲ្យជនរងគ្រោះស្លាប់ អង្គហេតុកើតនៅភូមិប្រធាតុ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម កាលពីថ្ងៃទី ០២.៦.២០១២ តាមមាត្រា ២១៨ និងមាត្រា ២២៤ នៃក្រមព្រហ្មទណ្ឌ ។

[redacted]

៤.គ.បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] ភ្លាម សងថ្លៃព្យាបាល និងជំងឺចិត្តទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] លីហ៊ាង ចំនួន ២០.០០០.០០០(ម្ភៃលាន)រៀល ។ ការទាមទារលើសពីនេះបដិសេធចោល ។

៥.ក.កែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ ៖

- [redacted]ចិន ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ(សាវតាជាតិដូចខាងលើ)
- [redacted]សាឯម ភេទប្រុស អាយុ ២០ឆ្នាំ ជាតិខ្មែរ(សាវតាជាតិដូចខាងលើ)

ពីបទឃាតកម្មគិតទុកជាមុន(មាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ) មកជាបទហិង្សាដោយចេតនាបណ្តាលឲ្យស្លាប់ជនរងគ្រោះ(មាត្រា ២២៤ នៃក្រមព្រហ្មទណ្ឌ) ។

[redacted]

៥.ខ.ផ្តន្ទាទោសជនជាប់ចោទឈ្មោះ ៖

- [redacted] ចិន ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ(សាវតាជាតិដូចខាងលើ)
- [redacted] សាឯម ភេទប្រុស អាយុ ២០ឆ្នាំ ជាតិខ្មែរ(សាវតាជាតិដូចខាងលើ)

ដាក់ពន្ធនាគារចំនួន ១២ឆ្នាំ ពីបទហិង្សាដោយចេតនាបណ្តាលឲ្យជនរងគ្រោះស្លាប់ អង្គហេតុកើតនៅភូមិប្រធាតុ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម កាលពីថ្ងៃទី ០២ ខែមិថុនា ឆ្នាំ ២០១២ តាមមាត្រា ២២៤ នៃក្រមព្រហ្មទណ្ឌ ។

៥.គ.បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] ភ្លាម ឈ្មោះ [redacted]ចិន និងឈ្មោះ [redacted] សាឯម រួមគ្នាសងជំងឺចិត្តទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] គុន ចំនួន ៤០.០០០.០០០(សែសិបលាន) រៀល ។ ការទាមទារលើសពីនេះបដិសេធចោល ។

៦.បង្គាប់ឲ្យចាប់ខ្លួនឈ្មោះ [redacted] ភ្លាម ឈ្មោះ [redacted]ចិន និងឈ្មោះ [redacted] សាឯម ភ្លាម តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៧.វត្ថុចាប់យក ៖

- ព្រនង់ឬស្សីទំហំ ១,៥០ស.ម គុណ ១,២០ម៉ែត្រ ចំនួន ០១
- ខ្សែក្រវ៉ាត់ពណ៌ក្រហមទំហំ ៣,៥០ស.ម គុណ ៩៤ស.ម (គ្មានក្បាល) ចំនួន ០១
- ខ្សែក្រវ៉ាត់ពណ៌ខ្មៅទំហំ ៣,៥០ស.ម គុណ ១០៣ស.ម(គ្មានក្បាល) ចំនួន ០១
- ស្បែកជើងសង្រែកទំហំ ៨,៥០ស.ម គុណ ២៧ស.ម(ពណ៌ខ្មៅ) ចំនួន ០១
- ស្បែកជើងសង្រែកទំហំ ៨,៥០ស.ម គុណ ២៦ស.ម(ពណ៌ខ្មៅ) ចំនួន ០១
- ស្បែកជើងសង្រែកទំហំ ៨,៥០ស.ម គុណ ២៧ស.ម(ពណ៌ត្រាវ) ចំនួន ០១
- បំណែកក្បាលខ្សែក្រវ៉ាត់ទំហំមុខកាត់ ០,៥០ស.ម ប្រវែង ០៨ស.ម ចំនួន ០១



Scanned with CamScanner

- បំណែកក្បាលខ្សែក្រវ៉ាត់ទំហំមុខកាត់ ០,៥០ស.ម ប្រវែង ០៥ស.ម ចំនួន ០១
- មួកប៉ារ៉េពណ៌ស ឆ្នូតខ្មៅ ផ្លាក Adidas ចំនួន ០១

ត្រូវរឹបអូស យោងតាមមាត្រា ២០៦ ចំណុច ៥ មាត្រា ២២៩ ចំណុច ៥ មាត្រា ៥៣ និងមាត្រា ៥៤ នៃក្រមព្រហ្មទណ្ឌ ។

៨.សាលក្រមនេះ ជំនុំជំរះនៅថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០១៧ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២៤ ខែសីហា ឆ្នាំ ២០១៧ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted]មាស ឈ្មោះ [redacted] ក្តាម ឈ្មោះ [redacted] ចុនា ឈ្មោះ [redacted] ចិន ឈ្មោះ [redacted] ប៊ី ហៅ ក្អែក និងឈ្មោះ [redacted] សាឯម និង ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]លីហ៊ាង ឈ្មោះ [redacted]ប៊ីមហួន និងឈ្មោះ [redacted] គុន ។ បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជំរះ** |
|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា | ហត្ថលេខា និងត្រា |
| [redacted] | [redacted] | [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

កំពង់ចាម ថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១៧

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជំរះ**

[redacted]